# អំពីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ

បើយក "រឿងធម្មបាលកុមារ" ជាសំអាងហេតុប្រារព្ធបុណ្យចូលឆ្នាំ នោះខ្មែរទូទៅចាំសាច់រឿងថា នាដើមភទ្ទកប្បមានបុរសម្នាក់ឈ្មោះធម្មបាល ជាអ្នកមានប្រាជ្ញាឈ្លាសវៃ រហូតធ្វើឱ្យកបិលមហាព្រហ្មចុះមកភ្នាល់ប្រស្នា "៣ខ" ដោយដាក់លក្ខខណ្ឌថា អ្នកចាញ់ត្រូវកាត់ក្បាលបូជាអ្នកឈ្នះ។ ប្រស្នានោះចោទថា "តើសិរីរបស់មនុស្សនៅត្រង់ណាខ្លះ?" ធម្មបាលកុមារបានលបព្ទសត្វឥន្ទ្រីជជែកគ្នាអំពីចម្លើយថា "សិរីពេលព្រឹកនៅមុខ ថ្ងៃត្រង់នៅទ្រូង និងល្ងាចនៅជើង"។ ដោយសារតែដឹងអាថ៌ប្រស្នានេះ ធម្មបាលកុមារក៏បានឈ្នះប្រស្នាកបិលមហាព្រហ្ម។ មុននឹងកាត់ព្រះសិរបូជាតាមសន្យា កបិលមហាព្រហ្មបង្គាប់ឱ្យបុត្រីទាំង៧អង្គ យកជើងពានទទួលព្រះសិរព្រះអង្គ ព្រោះបើធ្លាក់ដល់ដីនឹងឆេះលោកធាតុ បោះទៅលើមេឃនឹងរាំងភ្លៀង បោះក្នុងសមុទ្រនឹងរីងទឹកអស់។ ហេតុនេះទើបបុត្រីទាំង៧ ផ្លាស់វេនដង្ហែព្រះសិរបិតារៀងរាល់ឆ្នាំ ដែលនាំឱ្យកើតមានជាប្រពៃណីទេវតាឆ្នាំថ្មីយាងមកបន្តវេនគ្នាថែរក្សាលោកធាតុតាមថ្ងៃសង្ក្រាន្តរហូតមកដល់សព្វថ្ងៃ។[1] ព្រេងនិទាននេះក៏ឃើញមានគូរបង្ហាញនៅតាមព្រះវិហារវត្តមួយចំនួនដែរ (រូបលេខ១)។



រូបលេខ១ គំនូរពិធិដង្ហែព្រះសិរកបិលមហាព្រហ្ម គូរលើពិតានព្រះវិហារវត្តរកាអារ ខេត្តកំពង់ចាម

[1] គិម អាន, ១៩៣៨, ទំ.២១២-២២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ពាក់ព័ន្ធអំពីបុណ្យចុលឆ្នាំថ្មីប្រពៃណីខ្មែរដដែល បើមើលតាមកំណត់ហេតុ ជីវ តាក្វាន់ កត់ត្រាក្នុងចុងសតវត្សរ៍ទី១៣ លោកបានអធិប្បាយខ្លះទុកជាមូលដ្ឋានពិចារណាថា ខ្មែរតែងប្រារព្ធពិធីបុណ្យចូលឆ្នាំនៅក្នុងខែទី១ ដែលត្រូវនឹងខែទី១០ នៃប្រក្រតីទិនរបស់ចិន។ កំណត់ហេតុឱ្យដឹងបន្ថែមទៀតថា ខែទី១ ក្នុងសម័យនោះ គឺត្រូវនឹងខែកត្តិក។[2] ចំណេរតមក ការកំណត់ពេលចូលឆ្នាំបានលើកមកប្រារព្ធក្នុងខែចេត្រ រហូតមកដល់សព្វថ្ងៃ។ ប៉ុន្តែទោះជាដូចម្តេចក្តី ក៏ប្រពៃណីចូលឆ្នាំថ្មីក្នុងសង្គមខ្មែរ យើងសង្កេតឃើញមិនដែលប្រារព្ធធ្វើមិនមុនថ្ងៃ៤កើតខែចេត្រ ហើយក៏មិនដែលប្រារព្ធធ្វើក្រោយថ្ងៃ៤កើត ខែពិសាខដែរ។ ការត្រឡប់មកប្រារព្ធចូលឆ្នាំថ្មីនៅក្នុងវេលាពាក់កណ្តាលឆ្នាំបែបនេះ (ខែចេត្រ) មានសេចក្តីពន្យល់បកស្រាយថា ខែមិគ្គសិរជាខែដើមរដូវធ្វើស្រែចម្ការ ហើយខែចេត្រ កិច្ចការច្រូតកាត់បោកបែនបានចប់សព្វគ្រប់ ហើយប្រជាកសិករមានពេលទំនេរច្រើន មានឱកាសធ្វើបុណ្យទានកម្សាន្តសប្បាយតាមប្រាថ្នា។ ទំនៀមនេះក៏ចេះតែដក់ជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃ។[3]

បច្ចុប្បន្នខ្មែរតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំនេះ មានរយៈពេល៣ថ្ងៃ។ ថ្ងៃទី១ ហៅថា "ថ្ងៃចូលឆ្នាំ" ថ្ងៃទី២ ហៅថា "វារវ័នបត" ឬថ្ងៃកណ្តាល និងថ្ងៃទី៣ ជាថ្ងៃហៅថា "ថ្ងៃឡើងស័ក" ឬ "វារឡើងស័ក" ដែលទាំង៣ថ្ងៃនេះហៅថា "មហាសង្ក្រាន្ត" ឬ "សង្ក្រាន្តឆ្នាំថ្មី" ឬហៅជាទូទៅថា "ចូលឆ្នាំថ្មី"។ ក្នុងឱកាសនេះ គេសម្គាល់ឃើញតាមភូមិស្រុកនីមួយៗ តែងរៀបចំចាត់ចែងសម្អាតផ្ទះសម្បែងឱ្យមានសិរីសួស្តី ទទួលទេវតាឆ្នាំថ្មី។ តាមវត្តអារាម និងស្ថាប័ននានាតែងរៀបចំបដារស្វាគមន៍ ជូនពរសាទរឆ្នាំថ្មីផងដែរ។ គេត្រូវរៀបចំត្រៀមគ្រឿងសក្ការបូជាថ្វាយទេវតាឆ្នាំថ្មីដូចជា បាយសី ស្លាធម៌ ធូប ទៀន ទឹកអប់ ផ្កាភ្ញី លាជ ទឹក១ផ្តិល និងភេសជ្ជៈ នំនែក ផ្លែឈើគ្រប់មុខឱ្យបានត្រឹមត្រូវ។ គ្រឿងសក្ការៈនិងដង្វាយបូជាទាំងអស់នេះ តែងឃើញគេរៀបចំដាក់លើតុសមគួរមួយតាមផ្ទះរៀងៗខ្លួន និងតាមក្រសួង ស្ថាប័នតូចធំនានា។ ចូលដល់វេលាកំណត់ទេវតាឆ្នាំថ្មីយាងមកដល់ គេនាំគ្នាអុជទៀន ធូប នមស្ការ បួងសួង សុំសេចក្តីសុខចម្រើនគ្រប់ប្រការទៅតាមទំនៀម។

---

[2] ជីវ តាក្វាន់, ១៩៧៣ [លី ធាមតេង បកប្រែ], ទំ.៣៩-៤២

[3] ម៉ែន ប្រាជ្ញ និង អាំ ឆន, ១៩៩៤, ទំ. ៩២-១០១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# អត្ថបទ៖ អំពីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ

ក្នុងបំណងចូលរួមលើកតម្លៃទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងបង្កើនការជួបជុំសប្បាយក្នុងពិធីចូលឆ្នាំថ្មី ឬសង្ក្រាន្តឆ្នាំថ្មី ក្នុងប្រហែលជាង១០ឆ្នាំចុងក្រោយនេះប្រជាជនខ្មែរស្ទើរទូទាំងប្រទេសបានរៀបចំព្រឹត្តិការណ៍សង្ក្រាន្តឆ្នាំថ្មីតាមបណ្តាខេត្តនីមួយៗ ដែលមានគំរូព្រឹត្តិការណ៍អង្គរសង្ក្រាន្ត សម្តែងឱ្យឃើញទេពធីតាជាបុត្រីកបិលមហាព្រហ្មយាងចុះមកជាក់ស្តែងក្នុងទម្រង់ជាសិល្បៈផង(រូបលេខ២-៣)។ ការរៀបចំព្រឹត្តិការណ៍ទាំងនេះជាចំណែកដ៏ធំបង្ហាញឱ្យឃើញពីទិដ្ឋភាពពិធីចូលឆ្នាំខ្មែរទូទាំងប្រទេស ហើយថែមទាំងបង្ហាញពីការរៀបចំលេងល្បែងកម្សាន្តនានា និងសិល្បៈផ្សេងៗជាច្រើនទម្រង់ឱ្យយុវជនជំនាន់ក្រោយនិងភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិជិតឆ្ងាយបានស្គាល់ និងកម្សាន្តសប្បាយជាមួយប្រជាជនកម្ពុជា។



រូបលេខ២-៣ ទេពធីតាមហាសង្ក្រាន្តឆ្នាំថ្មី ខេត្តបាត់ដំបង និងទេពធីតាអង្គរសង្ក្រាន្តនៃឆ្នាំម្សាញ់(ឆ្នាំ២០២៥)

រីឯកិច្ចប្រតិបត្តិទាំង៣ថ្ងៃនៃពិធីបុណ្យចូលឆ្នាំ គេតែងយកចង្ហាន់ប្រគេនព្រះសង្ឃតាមវត្តអារាម និងពូនភ្នំខ្សាច់តាមប្រពៃណី (រូបលេខ៤)។ ទន្ទឹមនឹងនោះ តាមបណ្តាគ្រួសារខ្លះតែងជួបជុំគ្នា និមន្តព្រះសង្ឃធ្វើកិច្ចបង្សុកូលឧទ្ទិសកុសលដល់បុព្វការី ដែលបានចែកឋានទៅតាមទីអារាម ឬតាមចេតិយគ្រួសារនីមួយៗ។ យ៉ាងណាក្តីក្នុងថ្ងៃនីមួយៗបន្ទាប់ពីបំពេញកុសលរួចរាល់ គេតែងនាំគ្នាលេងល្បែងប្រជាប្រិយយ៉ាងសប្បាយរីករាយដូចជា បោះឈូង ទាញព្រ័ត្រ លាក់កន្សែង ចាប់កូនមាន់ ឡើងសសរ បោះអង្គញ់ សម្តែងគុនល្បុក្កតោ និងរាំលេងកម្សាន្តជាដើម (រូបលេខ៥-៦)។ ល្បែងប្រជាប្រិយទាំងអស់នេះខ្លះហាក់ដូចជាល្បែងកីឡា ខ្លះជាល្បែងបង្កប់ដោយខ្លឹមសារក្នុងបរិបទជំនឿ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤ កិច្ចបំបួសភ្នំខ្សាច់ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត រៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជា





រូបលេខ២៥-៦ ល្បែងវាយក្អម និងការសម្ដែងក្បាច់គុនល្បុក្កតោក្នុងព្រឹត្តិការណ៍សង្ក្រាន្តឆ្នាំថ្មី

ក្រៅពីលេងកម្សាន្តល្បែងប្រជាប្រិយផ្សេងៗដូចរៀបរាប់ត្រួសៗខាងលើ ក្នុងឱកាសចូលឆ្នាំថ្មី សង្គមខ្មែរតែងចាត់ទុកការ "រាំត្រុដិ" គឺជាល្បែងរបាំលេងក្នុងន័យផ្ដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី និងបណ្ដេញឧបទ្រពចង្រៃ។[4] បើតាមចំណាំ អ្នករាំត្រុដិគឺជាក្រុមមនុស្សស្រីប្រុសតែងខ្លួនជា ព្រាន ព្រាយ យក្ស ទន្សោង និងប្រើសជាដើម ហើយអ្នកស្រាវជ្រាវយល់ថារបាំនេះមានដើមកំណើតក្នុងខេត្តភាគខាងជើង ហើយល្បែងនេះជាប់ស្អិតទៅនឹងកិច្ចពិធី គឺ

[4] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ២០១៧:៥៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មិនមែនគ្រាន់តែលេងជាការសប្បាយពេល៣ថ្ងៃនោះទេ ដ្បិតការកាត់ផ្ដាច់សុទ្ធសឹងមានគំនិតក្នុងនោះថា ទាត់ចោល ឬកំទេចអ្វីមួយចាស់ ហើយទៅចាប់យកអ្វីមួយដែលថ្មី (រូបលេខ៧)។[5] បច្ចុប្បន្ន រាំត្រុដិហាក់ក្លាយជាទម្រង់សិល្បៈទស្សនីយភាពដ៏មានប្រជាប្រិយដែលគេសង្កេតឃើញនៅតាមបណ្ដាក្រសួង ស្ថាប័ន និងក្រុមហ៊ុននានា តែងរៀបចំទទួលក្រុមត្រុដិមកសម្ដែងជារឿយៗ(រូបលេខ៨)។ លុះឆ្លងចូលដល់ថ្ងៃបញ្ចប់ពិធីបុណ្យចូលឆ្នាំ គេច្រើននិមន្តព្រះសង្ឃផ្សឹកភ្នំខ្សាច់តាមទីអារាម និងរៀបចំជូនសម្លៀកបំពាក់ នំចំណីប្រាក់កាសដល់ឪពុកម្ដាយ ជីដូនជីតានៅតាមផ្ទះ។ ក្នុងវេលានោះ ពុទ្ធបរិស័ទក៏តែងនិមន្តព្រះសង្ឃស្រង់ទឹក ស្រង់ព្រះពុទ្ធរូប(ស្រង់ព្រះ) និងងូតជូនឪពុកម្ដាយ ឬចាស់ទុំក្នុងភូមិដោយទឹកអប់ផ្កាក្រអូបផង (រូបលេខ៩-១២)។



រូបលេខ៧ អ្នកស្រុកក្នុងខេត្តឧត្តរមានជ័យរាំត្រុដិតាមផ្ទះក្នុងរដូវចូលឆ្នាំ(រូបថត៖ អាន រស្មី)



រូបលេខ៨ របាំត្រុដិនាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ





[5] អាន រស្មី និង អាំង ជូលាន, ២០២២, ទំ.២៧-៤០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





*រូបលេខ៩-១២ កិច្ចស្រង់ទឹកព្រះពុទ្ធរូប និងផ្ងូតទឹកជូនអ្នកមានគុណ និងចាស់ព្រឹទ្ធាចារ្យក្នុងរដូវចូលឆ្នាំថ្មី*

សរុបមក បុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ គឺជាទំនៀមដែលចាក់ឫសយ៉ាងជ្រៅក្នុងប្រវត្តិសាស្ត្រ និងជំនឿតាមរយៈរឿងព្រេង "ធម្មបាលកុមារ និងកបិលមហាព្រហ្ម" ដែលជានិមិត្តរូបនៃការផ្លាស់ប្តូរទេវតាឆ្នាំថ្មីមកថែរក្សាឱ្យបានសេចក្តីសុខសប្បាយ។ ទន្ទឹមនេះពិធីបុណ្យចូលឆ្នាំបានបង្ហាញពីការផ្សារភ្ជាប់ការគោរពប្រតិបត្តិសាសនា និងជំនឿតាមរយៈការរៀបចំសក្ការបូជាទទួលទេវតា ការយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ការពូនភ្នំខ្សាច់ និងការងូតទឹកជូនឪពុកម្តាយ ឬចាស់ទុំ ដើម្បីសុំសេចក្តីសុខ។ ទន្ទឹមនឹងនោះដែរបុណ្យចូលឆ្នាំថ្មី បានបង្កឱកាសដល់យុវជនលេងល្បែងប្រជាប្រិយគ្រប់ទម្រង់ និងការរាំរបាំត្រុដិ ដែលមានអត្ថន័យក្នុងការបណ្តេញឧបទ្រពចង្រៃឆ្នាំចាស់។ ជារួមបុណ្យចូលឆ្នាំថ្មីមិនត្រឹមតែជាការផ្លាស់ប្តូរសករាជប៉ុណ្ណោះទេ តែគឺជាការបង្ហាញពីស្មារតីសាមគ្គីភាព ការដឹងគុណ និងការថែរក្សាមត៌កវប្បធម៌ដ៏សម្បូរបែបរបស់ជាតិឱ្យនៅគង់វង្ស៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

គិម អាន

១៩៣៨, "សេចក្ដីអធិប្បាយអំពីពាក្យថាសង្រ្កាន្ត", *កម្ពុជសុរិយា*, ឆ្នាំគម្រប់១០, ខែ ១, ២, ៣ រួមគ្នា, ការផ្សាយរបស់ព្រះរាជបណ្ណាល័យ, ភ្នំពេញ

ជីវ តាក្វាន់

១៩៧៣, *អំពីប្រពៃណីនៃអ្នកស្រុកចេនឡា*, [លី ធាមតេង បកប្រែ], រស្មីបដិវត្ត, ភ្នំពេញ

ម៉ែន ប្រាង និង អាំ ឆន

១៩៩៤, "បុណ្យចូលឆ្នាំខ្មែរ", *កម្ពុជសុរិយា*, លេខ១, ឆ្នាំទី៤៨, ទំ.៩២-១០១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អាន រស្មី និង អាំង ជូលាន

២០២២, "ត្រុដិ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៧, ទំ.២៧-៤០, យសោធរ, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត